# គោលការណ៍ណែនាំក្នុងពេលប្រឡងវិញ្ញាសារសរសេរសម្រាប់បេក្ខជន Teacher Training Students (TTS) និង Japanese Studies Students (JSS) នៃអាហារូបករណ៍រដ្ឋាភិបាលជប៉ុនឆ្នាំ២០២១ (MEXT 2021)

១. បេក្ខជនតម្រូវឲ្យមកដល់មណ្ឌលប្រឡង (ក្នុងបរិវេណស្ថានទូតជប៉ុន) ក្នុងចន្លោះពីម៉ោង ៨:១៥ នាទី ទៅ ៨:៤៥ នាទី។ បេក្ខជនដែលមកដល់ក្រោយម៉ោងកំណត់ខាងលើនឹងមិនអនុញ្ញាតឲ្យចូលមណ្ឌលប្រឡង ហើយបេក្ខជននឹងត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះប្រឡងដោយស្វ័យប្រវត្តិ។

២. មុនពេលចូលមណ្ឌលប្រឡង បេក្ខជនទាំងអស់នឹងត្រូវបានពិនិត្យកម្ដៅខ្លួនជាមុន។ ប្រសិនបើបេក្ខជនមានកម្ដៅខ្លួនលើសពី ៣៧.៥ អង្សា នោះបេក្ខជននឹងមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងមណ្ឌលប្រឡងនោះឡើយ។ បន្ថែមពីលើនេះ បេក្ខជនក្នុងផ្នែក TTS និង JSS សូមភ្ជាប់មកជាមួយនូវកាតសម្គាល់ខ្លួនដែលបញ្ជាក់ថាជាគ្រូបង្រៀន ឬជាសិស្ស-និស្សិតទៅតាមផ្នែករៀងៗខ្លួន។

៣. មានតែ ប៊ិច ខ្មៅដៃ ជ័រលុប និងដបទឹកពណ៌ថ្លាតែប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យដាក់លើតុប្រឡងបាន។ សូមរក្សាសម្ភារៈផ្ទាល់ខ្លួនមានដូចជា ទូរស័ព្ទដៃ នាឡិកា សៀវភៅគ្រប់ប្រភេទ ទៅក្នុងកាបូប-កាតាប និងទុកនៅខាងមុខបន្ទប់ប្រឡង។ សម្ភារៈមុតស្រួចដូចជា កាំបិត កន្ត្រៃ និងឧបករណ៍អេឡិចត្រូនិចដូចជា កុំព្យូទ័រយួរដៃជាដើម នឹងមិនត្រូវបានអនុញ្ញាតឲ្យយកចូលក្នុងមណ្ឌលប្រឡងនោះទេ។

៤. បេក្ខជនទាំងអស់ត្រូវពាក់ម៉ាសជាប់ជានិច្ចទាំងក្នុងពេលប្រឡង និងពេលនៅក្នុងបរិវេណមណ្ឌលប្រឡង និងត្រូវលាងដៃជាមួយទឹកអាល់កុលឲ្យបានត្រឹមត្រូវ។

៥. ក្នុងករណីដែលបេក្ខជនយកទូរស័ព្ទមកតាមខ្លួន សូមមេត្តាបិទទូរស័ព្ទជាដាច់ខាតមុនពេលចូលក្នុងមណ្ឌលប្រឡង។

៦. បេក្ខជនតម្រូវឲ្យចុះហត្ថលេខាលើបញ្ជីស្រង់វត្តមានមុនពេលចាប់ផ្តើមការប្រឡង។

៧. អនុរក្សនឹងធ្វើការចែកក្រដាសប្រឡងមុនពេលចាប់ផ្តើមការប្រឡង១០នាទី ប៉ុន្តែបេក្ខជនមិនត្រូវបើក ឬប៉ះក្រដាសប្រឡងរហូតដល់មានការអនុញ្ញាតពីអនុរក្ស ។

៨. បេក្ខជនត្រូវតែប្រគល់មកវិញទាំងអស់ជាដាច់ខាតនូវរាល់ក្រដាសវិញ្ញាសាដែលផ្តល់ជូនដោយអនុរក្សបន្ទាប់ពីចប់ការប្រឡងភ្លាមៗ។

៩. សូមបំពេញឈ្មោះជាភាសាអង់គ្លេស និងលេខតុដែលដូចទៅនឹងលេខរៀងក្នុងបញ្ជីឈ្មោះប្រឡងនៅលើគ្រប់វិញ្ញាសាទាំងអស់។

១០. នៅពេលដែលអនុរក្សប្រកាសម៉ោងបញ្ចប់ការប្រឡង សូមមេត្តាទម្លាក់ប៊ិច ឬខ្មៅដៃ និងរង់ចាំដោយស្ងៀមស្ងាត់រហូតដល់អនុរក្សប្រមូលវិញ្ញាសាប្រឡងរួចទើបបេក្ខជនអាចចាកចេញពីបន្ទប់ប្រឡងបាន។

១១. មុនពេលបញ្ចប់ការប្រឡងបេក្ខជននឹងមិនអនុញ្ញាតឲ្យចាកចេញពីបន្ទប់ប្រឡងបានឡើយ លើកលែងតែវិញ្ញាសាភាសាជប៉ុនតែប៉ុណ្ណោះដែលបេក្ខជនតម្រូវឲ្យអង្គុយក្នុងបន្ទប់ប្រឡងយ៉ាងតិច១៥នាទីសម្រាប់បេក្ខជនក្នុងផ្នែក TTS។

១២. បេក្ខជនក្នុងផ្នែក JSS នឹងមិនត្រូវបានជ្រើសរើសជាបេក្ខភាពជាប់តង់វិញ្ញាសា

សរសេរឡើយប្រសិនបើបេក្ខជនទទួលបានពិន្ទុសូន្យលើវិញ្ញាសាភាសាជប៉ុនរបស់ខ្លួន។

សូមអរគុណ!

ភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២១

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា